**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2022, 13:59
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ**/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបទៅនឹង "ការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះតុលាការកំពូលលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង០០២"**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

<u>នៅចំពោះមុខ</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

ទី ស្រ៊ីនណា

វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Fergal GAYNOR

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន

Anta GUISSÉ

## ១. សេចក្តីផ្តើម

1. សហហាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) កត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) បានចេញអនុស្សរណៈអន្តរការិយាល័យស្តីពី “ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២” (“អនុស្សរណៈ”) ដោយបានអញ្ជើញភាគីទទួលបានអនុស្សរណៈ ដាក់សេចក្តីសង្កេតរបស់ខ្លួនលើ (i) គោលការណ៍ណែនាំដែលបានស្នើឡើងសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និង (ii) អត្ថិភាពនៃការសម្ងាត់នៃកិច្ចស៊ើបសួរ[1]។ សហមេធាវីនាំមុខ សូមយកឱកាសនេះ ដើម្បីដាក់ជូននូវមតិយោបល់និងសេចក្តីសង្កេតរបស់ខ្លួន ជាភាគីនិងជាអង្គភាពមួយដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

## ២. សេចក្តីសង្ខេប

2. ជាការឆ្លើយតបទៅនឹងការអញ្ជើញរបស់អង្គជំនុំជម្រះឱ្យដាក់សេចក្តីសង្កេត សហមេធាវីនាំមុខរក្សាជំហរដូចបានលើកឡើងនៅក្នុង “សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី” (“សំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ”)[2]។ សហមេធាវីនាំមុខ ព្យាយាមមិនលើកឡើងចំណុចដដែលៗដូចបានបញ្ជាក់នៅក្នុងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខឡើយ ប៉ុន្តែជឿជាក់ថា ខ្លួនមានភាពចាំបាច់ត្រូវគូសបញ្ជាក់អំពីសេចក្តីសង្កេតសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងអនុស្សរណៈ។ ដូច្នេះ បន្ថែមលើសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ ក្រោយពីការពិគ្រោះយោបល់ជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំសូមដាក់ជូនសេចក្តីសង្កេតផ្សេងទៀតដូចតទៅ។

3. *ចំណុចទីមួយ* ជាផ្នែកមួយនៃគោលការណ៍ណែនាំរបស់ខ្លួនសម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលដំណើរការធ្វើចំណាត់ប្រភេទឡើងវិញ អង្គជំនុំជម្រះ បានស្នើឡើងថា “ភាគីដែលពាក់ព័ន្ធ រួមទាំង...អង្គភាពគាំពារជនរងគ្រោះ តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២...អាចស្នើសុំធ្វើចំណាត់ថ្នាក់សាឡើងវិញនូវឯកសារដែលសម្ងាត់ ឬ សម្ងាត់បំផុតក្រោយពីការបញ្ចប់នីតិវិធីធ្វើចំណាត់ឯកសារឡើងវិញ

---

[1] ឯកសារ **F71/1/1** អនុស្សរណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះតុលាការកំពូល ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ កថាខណ្ឌ ៥។

[2] ឯកសារ **F71** សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២១។

នេះ។ ក្នុងករណីនេះ ភាគីពាក់ព័ន្ធគប្បីបង្ហាញនូវកាលៈទេសៈដែលធ្វើយុត្តិកម្មដល់ការដាក់ចំណាត់ឯកសារឡើងវិញនេះ”[3]។ សហមេធាវីនាំមុខ សូមស្នើអង្គជំនុំជម្រះដាក់បញ្ចូលឲ្យបានជាក់លាក់ថាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីពាក់ព័ន្ធ ហើយថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតំណាង និងបំពេញកិច្ចជំនួសដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដោយមានជំនួយគាំទ្រ និងសម្របសម្រួលពី អ.គ.ជ។

4. *ចំណុចទីពីរ* ដោយអង្គជំនុំជម្រះស្នើថា ព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី គួរនៅតែរក្សា ឬធ្វើចំណាត់ប្រភេទជាឯកសារសម្ងាត់ដដែល[4]។ សហមេធាវីនាំមុខសូមដាក់ជូនថា ព័ត៌មានទំនាក់ទំនងលម្អិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅរក្សាឬធ្វើចំណាត់ប្រភេទជាឯកសារសម្ងាត់ដដែល។ ដូចបានរៀបរាប់នៅក្នុងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ[5] សារៈសំខាន់ក្នុងការការពារព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងជាក់លាក់ (“សេចក្តីណែនាំអនុវត្តស្តីពីការធ្វើណាត់ប្រភេទឡើងវិញ”)[6]។ លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានលើកឡើងថា ប្រសិនបើព័ត៌មានទំនាក់ទំនងលម្អិតរបស់ពួកគេត្រូវបានចេញផ្សាយជាសាធារណៈ ពួកគេអាចនឹងប្រឈមនឹងបញ្ហាដែលពួកគេមិនចង់ជួបប្រទះគឺការឆបោកតាមអ៊ីនធឺណិត និងទូរស័ព្ទ[7]។

5. *ចំណុចទីបី* ក្រៅពីព័ត៌មានទំនាក់ទំនងលម្អិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខស្នើអង្គជំនុំជម្រះពិនិត្យលើប្រភេទព័ត៌មានផ្សេងទៀត ដែលដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញការព្រួយបារម្ភ

---

[3] ឯកសារ **F71/1/1** អនុស្សរណៈ កថាខណ្ឌ ៤។

[4] *ដូចខាងលើ*។

[5] ឯកសារ **F71** សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៧,២៨, ៣៨។

[6] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ មាត្រា ៧.២, ៧.៣។

[7] ឯកសារ **F71** សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៨។

ព័ត៌មានកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ[8] ព័ត៌មានវេជ្ជសាស្ត្រផ្ទាល់ខ្លួន[9] បទពិសោធន៍ និងទស្សនៈស្តីពីការរៀបការដោយបង្ខំ[10] សម្ភារៈដែលទទួលបានតាមរយៈការធ្វើទារុណកម្ម រួមទាំងចម្លើយសារភាព និងប្រវត្តរូប[11] និងការកំណត់ឈ្មោះចារីដែលត្រូវបានសង្ស័យ[12]។ ឯកសារភាគច្រើននៅក្នុងប្រភេទទាំងនេះស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ ពោលគឺ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមានភស្តុតាងនៅក្នុងសំណុំរឿង ដែលតាមការសន្មតអាចធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈបាន ប៉ុន្តែមានព័ត៌មានដែលមានលក្ខណៈរសើប និងឯកជន ហើយមិនស្ថិតនៅក្នុងផ្នែកណាមួយនៃប្រភេទសម្ភារៈសម្ងាត់ អនុលោមតាមមាត្រា ៥ មាត្រា ៦ និងមាត្រា ៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[13]។ មួយវិញទៀត ឯកសារដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅក្នុងសំណុំរឿងហាក់ដូចជាមិនត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ ឬសម្ងាត់ឡើយ អនុលោកតាមសេចក្តីណែនាំការអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ[14]។

6. នៅក្នុងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំអនុវត្តវិធីសាស្ត្រសម្រាប់ឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងភស្តុតាង ដូចខាងក្រោម៖

   ហេតុដូច្នេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ E3 គួរតែត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ យោងតាមគោលការណ៍ដូចខាងក្រោម៖

   (i) ជាភស្តុតាង អ្វីៗទាំងអស់ត្រូវបានសន្មតថាជាសាធារណៈ ប៉ុន្តែស្ថិតក្រោមការកោសលុប តាមការចាំបាច់។

---

[8] *ដូចខាងលើ* កថាខណ្ឌ ៣៩។

[9] *ដូចខាងលើ* កថាខណ្ឌ ៤០។

[10] *ដូចខាងលើ* កថាខណ្ឌ ៤១។

[11] *ដូចខាងលើ* កថាខណ្ឌ ៤២។

[12] *ដូចខាងលើ* កថាខណ្ឌ ៤៣។

[13] *ដូចខាងលើ* កថាខណ្ឌ ៤៦។

[14] *ដូចខាងលើ*។

(ii) កម្មវត្ថុដែលស្ថិតក្រោមប្រធានបទទាំងអស់ ដែលបានកំណត់នៅក្នុងផ្នែកទី៤.២[15]ខាងលើ គួរសន្មតថាត់ទុកថាតម្រូវឲ្យមានការកោសលុប។

(iii) ប៉ុន្តែ នៅក្នុងករណីនីមួយៗ បញ្ហាទាំងនេះអាចទុកចំហរមិនកោសលុបះ ឧទាហរណ៍ នៅក្នុងករណីដែលសម្ភារៈត្រូវធ្វើឲ្យទៅជាឯកសារសាធារណៈ តាមរយៈសក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ឬ នៅក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមដោយបានយល់ដឹង[16]។

7. ចំពោះឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមាននៅក្នុងភស្តុតាង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា ឯកសារទាំងនេះមិនចាំបាច់សន្មតធ្វើឲ្យទៅជាឯកសារសាធារណៈនោះឡើយ ប៉ុន្តែគួរតែធ្វើឲ្យទៅជាឯកសារសាធារណៈ ដោយផ្អែកលើគោលការណ៍យល់ព្រមជាបុគ្គល ក្នុងករណីដែលការយល់ព្រមនោះត្រូវបានជូនដំណឹងពេញលេញ[17]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមិនស្ថិតក្នុងភស្តុតាង គួរតែនៅរក្សាសម្ងាត់ដដែល លើកលែងតែមានសំណើជាបុគ្គលរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ ដែលស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយស្ថិតនៅក្រោមការកោសលុបតាមការស្នើសុំ[18]។ គោលការណ៍នៃឯកជនភាព និងការយល់ព្រមដែលផ្តល់ជាមួយនឹងការកោសលុបនៃឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ត្រូវបានអនុវត្តមុននឹងការធ្វើចំណាត់ថ្នាក់ឯកសារផ្សេងៗ។[19]

8. *ចំណុចទីបួន* ដូចបានកត់សម្គាល់នៅក្នុងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈដោយមិន

---

[15] ទាំងនេះជាប្រធានបទដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៥ និងកថាខណ្ឌ ៦ នៃចម្លើយតបនេះ។

[16] ឯកសារ F71 សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦៩។

[17] *ដូចខាងលើ* កថាខណ្ឌ ៧៣។

[18] *ដូចខាងលើ* កថាខណ្ឌ ៧៥។

[19] *សូមមើល* ឧបសម្ព័ន្ធសម្ងាត់ ក ដែលភ្ជាប់ជាមួយសំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានតារាងបញ្ជីឧទាហរណ៍នៃឯកសារដើមបណ្តឹងរដ្ឋប្បវេណី ដែលបង្ហាញពីតម្រូវការសម្រាប់ដំណើរការធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញដោយប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការពិនិត្យឯកសារបុគ្គល និងឱកាសសម្រាប់ភាគីដែលរងផលប៉ះពាល់ ដែលត្រូវបានដឹងឮ។

មានការកោសលុប[20]។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះបង្គាប់ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាបន្ទាន់ជាឯកសារសម្ងាត់ (រហូតដល់ និងផ្អែកតាមលទ្ធផលនៃដំណើរការធ្វើចំណាត់ប្រភេទឡើងវិញពេញលេញ) លើឯកសារដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងរឿងក្ដីទាំងអស់ដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញ ជាឯកសារសាធារណៈដោយកំហុស ឬដោយគ្មានការកោសលុបត្រឹមត្រូវ ដែលរំលោភលើសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញ[21]។

9. *ចំណុចទីប្រាំ* ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ មួយចំនួន ទទួលបានឋានៈ នៅក្នុងសំណុំរឿងមួយ ឬច្រើនផ្សេងទៀត វិធីសាស្ត្ររួមក្នុងការធ្វើចំណាត់ប្រភេទឡើងវិញនៅគ្រប់សំណុំរឿងទាំងអស់របស់ អ.វ.ត.ក គឺជាការចាំបាច់ផងដែរ។ ដូច្នេះការធ្វើចំណាត់ថ្នាក់មួយដែលបានផ្ដល់ឱ្យក្នុងសំណុំរឿងមួយ នឹងមិនត្រូវបានប៉ះពាល់ដោយការធ្វើចំណាត់ថ្នាក់មិនមានសង្គតិភាពមួយនៅក្នុងសំណុំរឿងមួយផ្សេងទៀតទេ[22]។

10. *ចំណុចចទីប្រាំមួយ* សហមេធាវីនាំមុខសូមកត់សម្គាល់ជូនអង្គជំនុំជម្រះថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំឱ្យមានដំណើរការនានានៅក្នុងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញរបស់សហមេធាវីនាំមុខ[23]។ សរុបមក ជំហានក្នុងដំណើរការនេះរួមមាន: (i) ការពិនិត្យពេញលេញទៅលើឯកសារដើម្បីកំណត់អត្តសញ្ញាណព័ត៌មានរសើប ដែលនៅក្នុងអំឡុងពេលនេះ ឯកសារនៅក្នុងភស្តុតាងនឹងត្រូវបានផ្តល់អាទិភាព។ (ii) នៅពេលដែលមានវិមតិសង្ស័យថាតើការកោសលុបឡើងមានភាពចាំបាច់ដែរឬទេ គួររៀបចំកិច្ចប្រជុំជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីពិគ្រោះយោបល់ជាមួយពួកគាត់អំពីការចង់បានរបស់ពួកគាត់ ដែលក្នុងអំឡុងពេលនោះ សម្ភារៈដែលមិនមែនជាភស្តុតាងនឹងត្រូវយកមកពិភាក្សាផងដែរ។ (iii) សំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ និងការកោសលុបឯកសារដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងភស្តុតាង នឹងត្រូវដាក់ជូនអង្គជំនុំជម្រះ ដែលពេលនោះអង្គជំនុំជម្រះអាចសម្រេច ក្នុងពេលសមស្រប និងដោយគិតពិចារណាលើចម្លើយតបរបស់ភាគីផ្សេងទៀត។ និង (iv) នៅ

---

[20] ឯកសារ F71 សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីកថាខណ្ឌ ៤៨-៥៣។

[21] *ដូចខាងលើ* កថាខណ្ឌ ៨៦(ង)។

[22] *ដូចខាងលើ* កថាខណ្ឌ ៧៨។

[23] *ដូចខាងលើ* កថាខណ្ឌ ៨៥។

ពេលដែលសារណាត្រូវបានធ្វើឡើងលើសម្ភារៈភស្តុតាង ដំណើរការទៅមុខទៀតដែលអនុវត្តតាមវិធីសាស្ត្រស្រដៀងគ្នានេះ នឹងត្រូវបានផ្តួចផ្តើមឡើងដើម្បីដោះស្រាយលើសម្ភារៈដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ ដែលមិនមាននៅក្នុងភស្តុតាង[24]។

11. *ចំណុចទីប្រាំពីរ* សហមេធាវីនាំមុខកត់សម្គាល់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ.គ.ជ បានជួបដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៤២ រូប នៅក្នុងវេទិកាដើមបណ្តឹងរដ្ឋប្បវេណីនិងការប្រជុំពិគ្រោះយោបល់ ពីខែតុលា ឆ្នាំ ២០២១ ដល់ខែសីហា ឆ្នាំ២០២២ ដើម្បីពិគ្រោះយោបល់និងទទួលមតិយោបល់របស់ពួកគាត់អំពីការចាត់ចំណាត់ថ្នាក់ឡើងវិញនូវឯកសារ ឬព័ត៌មានរបស់ពួកគាត់។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤២ រូប បានស្នើសុំថា ចំពោះព័ត៌មានមួយចំនួនដែលជាព័ត៌មានឯកជនភាព ឬជាព័ត៌មានរសើប ដែលបានលើកឡើងនៅក្នុងឯកសាររបស់ពួកគាត់ ដូចជាព័ត៌មានអំពីថ្ងៃខែឆ្នាំកំណើត ព័ត៌មានទំនាក់ទំនង ព័ត៌មានេកជនភាពនិងព័ត៌មានរសើបនៃសមាជិកគ្រួសារ ព័ត៌មានវេជ្ជសាស្ត្រនិងសុខភាព ព័ត៌មានជុំវិញការរំលោភបំពានផ្លូវភេទនិងការបង្ខំរៀបការដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះរបស់បុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និងរូបថតផ្សេងៗទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់និងត្រូវកោសលុប។ សហមេធាវីនាំមុខសូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះដែលសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជួបពិគ្រោះយោបល់ បានបង្ហាញថា ព័ត៌មានឯកជនភាព និងព័ត៌មានរសើបរបស់ពួកគាត់ត្រូវតែការពារ។

## ៣. សំណើ

12. ផ្អែកលើសេចក្តីសង្កេតខាងលើ សហមេធាវីនាំមុខគោរពស្នើសុំអង្គជំនុំជម្រះមេត្តា៖

(ក) **គាំទ្រ** គោលការណ៍នៃឯកជនភាព និងការយល់ព្រមដែលទទួលបានព័ត៌មានគ្រប់គ្រាន់ ពាក់ព័ន្ធនឹងការកោសលុបឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង មុនពេលមានការធ្វើចំណាត់ប្រភេទឡើងវិញណាមួយ។

[24] *ដូចខាងលើ*។

(ខ) **បញ្ជាក់** ថា ឯកសារដើមបណ្ដឹងរដ្ឋប្បវេណីដែលស្ថិតនៅក្រៅខ្លឹមសារមាត្រា៤ នៃសេចក្ដីណែនាំអនុវត្ត នឹងមិនត្រូវធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈដោយគ្មានសំណើ បង្ហាញពីការយល់ព្រមដែលទទួលបានព័ត៌មានគ្រប់គ្រាន់ពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធឡើយ។

(គ) **បង្គាប់** ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាបន្ទាន់ជាឯកសារសាធារណៈ (រហូតដល់ និង ផ្អែកតាមលទ្ធផលនៃដំណើរការធ្វើចំណាត់ប្រភេទឡើងវិញពេញលេញ) លើឯកសារដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងរឿងក្ដីទាំងអស់ដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញថាសាធារណៈ ដោយកំហុស ឬដោយគ្មានការកោសលុបត្រឹមត្រូវដែលរំលោភលើសេចក្ដីណែនាំអនុវត្ត។

សូម លោក-លោកស្រីចៅក្រម ទទួលយកចម្លើយតបនេះដោយការគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |